ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៧-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ០៤ រូប ៩៥៨៨

០៧-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៥ ស្ដីពី ការតែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ៩៥៨៩

០៧-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ ចំនួន ១១ រូប ៩៥៩០

០៧-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ១២ រូប ៩៥៩១

១០-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០២៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេនចំពោះ ព្រះគ្រូ **នុត វណ្ណៈ** ព្រះអនុគណស្រុកបាភ្នំ និង ជាព្រះចៅអធិការវត្តជ្រៃឧត្តម ៩៥៩២

១០-១២-២០១២ - ព្រះរាជក្រឹត្យ នស/រកត/១២១២/១០៣០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឧត្តមសេនីយ៍ឯក **ពិន ណារិទ្ធ** ៩៥៩៣

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

០៤-១២-២០១២ - អនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្ដីពី ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣ ៩៥៩៤

០៥-១២-២០១២ - អនុក្រឹត្យលេខ ២២៧ អនក្រ.បក ស្ដីពី ការកាត់ដីសរុបទំហំ ៦៨២,៤៥ ហិកតា ចេញពីតម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៥៥ គ្រួសារ និង ផ្ដល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះ ជាក់ស្ដែងចំនួន ៤៤៨ គ្រួសារ លើដី ៦១៨ ក្បាលដី នៅស្រុក ដំណាក់ចង្អើរ ខេត្តកែប ៩៥៩៩

០៥-១២-២០១២ - អនុក្រឹត្យលេខ ២២៨ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៩៦០៧

០៥-១២-២០១២-អនុក្រឹត្យលេខ ២២៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៨៥៤,៣២៩៩ ហិកតា នៅស្រុកអណ្តូងមាស និង ស្រុកបរកែវ ខេត្តរតនគិរី ពីក្រុមហ៊ុន ហេង ប្រាឌ៉ុរ និង ក្រុមហ៊ុន វ៉ាសនា អ៊ិនវេសមេន ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និង រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង សំណើសុំផ្តល់សិទ្ធិលើក្បាលដី ៩៦០៩

០៥-១២-២០១២-អនុក្រឹត្យលេខ ២៣០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦១៣

០៦-១២-២០១២-អនុក្រឹត្យលេខ ២៣១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦១៥

០៧-១២-២០១២-អនុក្រឹត្យលេខ ២៣២ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦១៧

០៧-១២-២០១២-អនុក្រឹត្យលេខ ២៣៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦១៩

០៧-១២-២០១២-អនុក្រឹត្យលេខ ២៣៤ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៤៤៨ ហិកតា ដែលក្នុងនោះ (១) កាត់ចេញពីឧទ្យានជាតិកែប នៃព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣, (២) ពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ នូវទំហំ ៤២៧ ហិកតា សម្រាប់ធ្វើ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៤៥ គ្រួសារ និង ទំហំ ២១ ហិកតា រក្សាទុកសម្រាប់ជាដីឯកជនរបស់រដ្ឋ សម្រាប់សម្បទានគោលដៅសង្គមកិច្ច និង ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង ចំនួន ២៣៣ គ្រួសារ លើ ៤៣៦ ក្បាលដី នៅក្រុងកែប ខេត្តកែប ៩៦២១

០៧-១២-២០១២-អនុក្រឹត្យលេខ ២៣៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦២៥

២៦-១០-២០១២-អនុក្រឹត្យលេខ ២០៩៨ អនក្រ.តត ស្តីពី ការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៩៦២៧

២៦-១០-២០១២-អនុក្រឹត្យលេខ ២០៩៩ អនក្រ.តត ស្តីពី ការតែងតាំង និង តម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩៦២៨

៣០-១០-២០១២-អនុក្រឹត្យលេខ ២១០០ អនក្រ.តត ស្តីពី ការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៦២៩

៣០-១០-២០១២-អនុក្រឹត្យលេខ ២១០១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៦៣១

០១-១១-២០១២-អនុក្រឹត្យលេខ ២១០២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៩៦៣២

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៩៦៣៦

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៦៣៨

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៦៣៩

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៦៤០

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៦៤១

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៦៤៤

០១-១១-២០១២-អនុក្រឹត្យលេខ ២១០៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៦៤៥
០១-១១-២០១២-អនុក្រឹត្យលេខ ២១១០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៦៤៦
០១-១១-២០១២-អនុក្រឹត្យលេខ ២១១១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ មន្ត្រីរាជការ ៩៦៤៧
០១-១១-២០១២-អនុក្រឹត្យលេខ ២១១២ អនក្រ.តត ស្តីពី ការតែងតាំង និង ប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ៩៦៤៩
០១-១១-២០១២-អនុក្រឹត្យលេខ ២១១៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៦៥០
០១-១១-២០១២-អនុក្រឹត្យលេខ ២១១៤ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ៩៦៥១
០១-១១-២០១២-អនុក្រឹត្យលេខ ២១១៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៦៥៣
០១-១១-២០១២-អនុក្រឹត្យលេខ **២១១៦** ដល់អនុក្រឹត្យលេខ **២១៣២** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩៦៥៤

២-សេចក្តីសម្រេច

១៩-១២-២០១២-សេចក្តីសម្រេចលេខ ៤៨ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៩៦៧១

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៣-១១-២០១២-ប្រកាសលេខ ១១៦០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បេសវេយ អ៊ិនដាសស្ត្រាល បង្កើតរោងចក្រ ផលិតកង់ ៩៦៧២
២៣-១១-២០១២-ប្រកាសលេខ ១១៦១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាយ ស្តារ ខតថិន ហ្គាមេន (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩៦៧៦
២៣-១១-២០១២-ប្រកាសលេខ ១១៦២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាម៉ាតុ គុនពូ អ៊ិនធើណេសិនណល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារះវេចខ្ចប់ពីក្រដាសកាតុង ៩៦៨០
០៣-១២-២០១២-ប្រកាសលេខ ១១៨១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាងវ៉ូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៩៦៨៤

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៥២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តារម្យ ខនស្ត្រាក់សិន** ៩៦៨៨
២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីស្ទីង ហាខេស (ខេមបូឌា) ខូ អិលធីឌី** ៩៦៩០

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៥៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីន ឈ័យ (ខេមបូឌា) ខូ លីមីធីត** ៩៦៩២

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាល់ត្រា ស្រ្វែធីជី (ខេមបូឌា) ខូ អិលធីឌី** ៩៦៩៤

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាតអិនច្ធ អ៊ិនទេសមេន** ៩៦៩៦

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បាយ័ន ក្រេឌីត លីមីធីត** ៩៦៩៨

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៧៦ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ស៊ីរី សែន (ខេមបូឌា) លីមីធីត** ៩៧០០

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៧៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ឌី ប៊ី ហ្វីដ មីល** ៩៧០២

២១-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភីភីអេសអិល អ៊ែតវើថាយ ស៊ីុខ ខូ អិលធីឌី** ៩៧០៤

២២-៧-២០១១ -លិខិតបញ្ជាក់លេខ ៤២៨២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីុខ ប៊ុនហួរ កសិ-ឧស្សាហកម្ម ខូ អិលធីឌី** ៩៧០៦

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយដឹកនាំប្រយុទ្ធ
និងត្រៀមប្រយុទ្ធការពារបូរណភាពទឹកដីទិសប្រាសាទព្រះវិហារ តាមទ្ក តាក្របី

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

១-ឧត្តមសេនីយ៍ឯក	លី	ជេត	អត្តលេខ ០០០០២៩
២-ឧត្តមសេនីយ៍ឯក	ម៉ម	សំ	អត្តលេខ ០០២៥១២
៣-ឧត្តមសេនីយ៍ឯក	កែវ	សុភគី	អត្តលេខ ០០២៣៥២
៤-ឧត្តមសេនីយ៍ឯក	កែវ	សាប៊ិន	អត្តលេខ ០០៣៨៧៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៩៩៥ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊យ សុខា

ពរស.១២១២.១០៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា :

១- ឯកឧត្តម ជា ចំរុង មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម ឯក សុខុម មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម ស៊ឹម សៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១២១២.១០៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

លេខ:៩៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១២
[illegible]ទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ ចំនួន ១១រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច
បម្រើជាតិមាតុភូមិកន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ :
- លោកជំទាវ ច្រាក់ ចន្ថា

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ម៉ម ធណ្ណះ ២- ឯកឧត្តម ទ៉ា ស៊ីមសិរីទ្ធ

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ម៉ៅ សម្បត្តិ ៣- លោកជំទាវ ស៊ើង សរសុចិន្តា
២- ឯកឧត្តម ចាប ឫទ្ធី ៤- ឯកឧត្តម រ័ត្ន ប៊ុនឡា

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តម សាត សមុទ្រ ៣- ឯកឧត្តម អៀង សុផល
២- ឯកឧត្តម ប៊ុក ផាន់

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :
- ឯកឧត្តម ឡេង សែ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

ពរស. ១២១២.១០៧៦

លេខៈ ៩៩១ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ១២រូប ដែលមានស្នាដៃល្អក្នុងការសាងសង់ផ្លូវជាតិ លេខ៧៨ ពីអូរពងមាន់ ខេត្តស្ទឹងត្រែង ដល់ក្រុងបានលុង ខេត្តរតនគិរី ប្រវែង ១២៦ គ.ម សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ស៊ុយ សាន
២- លោក ថន សាធុន
៣- លោក សូ សំណាង
៤- លោក សរ គឹមណាត
៥- លោក អ៊ុក ចំនួតារា

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោក ទ៉ែត រដ្ឋា
២- លោក សាយ សាមាន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ចាន់ តារា
២- លោក ត្រាំ ណារ៉ាន់
៣- លោក ស៊ឹម សំណាង
៤- លោក គង់ សុធា
៥- លោកស្រី ម៉ាញ សុខសម្ភារ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/១២១២/១០៦៧

លេខ:៧៩៥ ប.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការគណៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល

សយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ប្រគេន

ព្រះគ្រូ នួត ខណ្ឌៈ

ព្រះអនុគណស្រុកបាភ្នំ និងជាព្រះចៅអធិការវត្តជ្រៃឧត្តម ដែលមានព្រះគុណបំណាច់
និងស្នាព្រះហស្ត ចំពោះជាតិ និងសាសនា ដោយបានបរិច្ចាគបច្ច័យចូលរួមជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា នៅស្រុកបាភ្នំ ខេត្តព្រៃវែង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៨-១៤១៤-១០៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២

លេខ ៩៩២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១២/១០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឧត្តមសេនីយ៍ឯក ពិន ណារិទ្ធ អត្តលេខ 000៤៦៥

ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន ក្នុងការចូលរួមចំណែកកសាង
អភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧៣៧-១២១២-១០៤០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១២

លេខ: ៩៩០ ច.ល
ផ្ញើថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ ធ្នូ ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៦. អនុក្រ. បក

អនុក្រឹត្យ

ស្តីពី

ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលបំណងពង្រឹងនិងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិកសិកម្ម ដើម្បីទទួលបាននូវព័ត៌មានគ្រប់ផ្នែកក្នុងវិស័យកសិកម្មនិងធ្វើជាទិន្នន័យមូលដ្ឋានសម្រាប់អ្នកប្រើប្រាស់និងអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងនានា ដើម្បីជំរុញកិច្ចអភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច។

មាត្រា ២.-

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣។

មាត្រា ៣.-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើគ្រប់ការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្មទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤.-

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ការកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់អង្គភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្ម ក្រោមការគ្រប់គ្រងតែមួយ រួមមានរាល់ដំណាំគ្រប់ប្រភេទ បសុសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រីចិញ្ចឹមគ្រប់ប្រភេទ វារីវប្បកម្ម និងរាល់ដីធ្លីបានប្រើប្រាស់ទាំងមូលឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពីកម្មសិទ្ធិ ឬទម្រង់ផ្លូវច្បាប់។ ការកាន់កាប់ផលិតកម្មកសិកម្មអាចមានក្បាលដីមួយឬច្រើន ដែលស្ថិតនៅក្នុងតំបន់មួយឬច្រើនដោយឡែកពីគ្នាក្នុងខេត្តតែមួយ ឬក្នុងតំបន់គ្រួតត្រាមួយឬច្រើន ឬតំបន់រដ្ឋបាលនៃប្រទេស ដែលមានក្បាលដីប្រើមធ្យោបាយផលិតកម្មតែមួយ ដូចជាពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬសត្វអូសទាញ។
- **ជំរឿនកសិកម្ម** សំដៅដល់ការប្រមូលទិន្នន័យអំពីការប្រើប្រាស់ដីធ្លី ការដាំដុះដំណាំគ្រប់ប្រភេទ ការចិញ្ចឹមសត្វគ្រប់ប្រភេទ ជលផល និងវារីវប្បកម្មក្នុងរយៈពេលយោងជាក់លាក់។
- **អ្នកកាន់កាប់ផលិតកម្មកសិកម្ម** សំដៅដល់គ្រួសារ ឬនីតិបុគ្គលដែលគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ លើការប្រតិបត្តិនៃការកាន់កាប់ផលិតកម្មកសិកម្ម។

ជំពូកទី២
កាលបរិច្ឆេទ

មាត្រា ៥.-

កាលបរិច្ឆេទជំរឿនកសិកម្ម ឆ្នាំ២០១៣ កំណត់នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣។

ជំពូកទី៣
យន្តការនិងនីតិវិធី

មាត្រា ៦.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រី ក្រសួងផែនការ ប្រធាន
- រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប អនុប្រធាន
- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ១រូប អនុប្រធាន
- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប អនុប្រធាន
- រដ្ឋលេខាធិការ ក្រសួងផែនការ ១រូប អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងបរិស្ថាន ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងធនធានទឹកនិងឧតុនិយម ១រូប សមាជិក
- រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ១រូប សមាជិក
- អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ លេខាធិការ ។

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការជាតិជំរឿនកសិកម្ម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា ៧.-

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ ត្រូវបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម គណៈកម្មការឃោសនាជំរឿនកសិកម្ម និងគណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត ដែលកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិជំរឿនកសិកម្ម។

មាត្រា ៨.-

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ មានភារកិច្ច៖

- ណែនាំ និងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនកសិកម្ម
- រៀបចំនិងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនកសិកម្ម និងគណៈកម្មការឃោសនាជំរឿនកសិកម្មមានទីស្នាក់ការនៅក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការជំរឿនកសិកម្ម
- រៀបចំនិងបង្កើតគណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត
- ចាត់តាំងមន្ត្រីឲ្យចូលរួមជំរឿនកសិកម្ម តាមការស្នើសុំរបស់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
- ប្រជុំការងារយ៉ាងតិច៦(ប្រាំមួយ)ខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន
- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅនិងលទ្ធផលនៃជំរឿនកសិកម្ម។

មាត្រា ៩.-

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ មានទីតាំងនៅក្រសួងផែនការនិង[illegible] របស់ក្រសួងផែនការ។

គណៈកម្មការបច្ចេកទេសជំរឿនកសិកម្មនិងគណៈកម្មការឃោសនាជំរឿនកសិកម្ម មានសិទ្ធិប្រើត្រារបស់ក្រសួងផែនការ។

គណៈកម្មាធិការជំរឿនកសិកម្ម រាជធានី ខេត្ត មានសិទ្ធិប្រើត្រារបស់រាជធានី ខេត្ត។

មាត្រា ១០.-

ប្រធានគណៈកម្មាធិការជាតិជំរឿនកសិកម្មមានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងប្រជាជន ដើម្បីសហការជួយធ្វើកិច្ចការជំរឿនកសិកម្ម។

មាត្រា ១១.-

ជំរឿនកសិកម្ម ឆ្នាំ២០១៣ ត្រូវមានដំណាក់កាលដូចតទៅ៖

១- កិច្ចប្រតិបត្តិការដំបូងរបស់ការជំរឿនមាន៖

- ការរៀបចំផែនទី
- ការធ្វើអង្កេតនិងជំរឿនសាកល្បង។

២- ការធ្វើសម្ភាសការកាន់កាប់ផលិតកម្មកសិកម្មនិងអ្នកកាន់កាប់ផលិតកម្មកសិកម្ម។

៣- កិច្ចប្រតិបត្តិការចុងក្រោយរបស់ការជំរឿនមាន៖

- ការធ្វើអង្កេតសម្រាប់វាយតម្លៃលើការជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀតក្នុងករណីចាំបាច់។

មាត្រា ១២.-

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទទួលបន្ទុកការងារជំរឿនកសិកម្មនិងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរផែនការនិងមន្ទីរកសិកម្ម រាជធានី ខេត្ត ជួយរាល់ការងារក្នុងការជំរឿន។

មាត្រា ១៣.-

មន្ត្រីបំពេញការងារជំរឿន រួមមានអ្នកត្រួតពិនិត្យការសម្ភាស អ្នកសម្ភាសស្រង់យកព័ត៌មាន និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការធ្វើជំរឿន ត្រូវចាត់តាំងដោយគណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ តាមការស្នើសុំរបស់អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ។ ការចាត់ចែងនេះអនុវត្តបានតែក្នុងអំឡុងពេលធ្វើជំរឿនតែប៉ុណ្ណោះ។

មាត្រា ១៤.-

អ្នកកាន់កាប់ផលិតកម្មកសិកម្ម ត្រូវសហការនិងអនុញ្ញាតឲ្យមន្ត្រីបំពេញការងារជំរឿនដែលបង្ហាញលិខិតបេសកកម្មផ្លូវការ បានចូលក្នុងទីតាំងនៃផលិតកម្មកសិកម្ម លំនៅឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការជំរឿន និងអនុញ្ញាតឲ្យមន្ត្រីទាំងនោះអាចលាបពណ៌ បិទអក្សរ បិទសញ្ញាឬលេខសម្គាល់នៅតាមកន្លែងចាំបាច់ សម្រាប់បម្រើដល់ការងារជំរឿនកសិកម្ម។

មាត្រា ១៥.-

គណៈកម្មាធិការជាតិជំរឿនកសិកម្ម ឆ្នាំ២០១៣ អាចចាត់តាំងអ្នកគ្រប់គ្រងជំរឿនកសិកម្ម តាមទីកន្លែងដែលមានលក្ខណៈពិសេសដូចខាងក្រោម៖

ក- អ្នកគ្រប់គ្រងទីតាំងនៃផលិតកម្មកសិកម្មសាធារណៈនិងឯកជនដែលមានទ្រង់ទ្រាយធំ។

ខ- អ្នកគ្រប់គ្រងផលិតកម្មកសិកម្មផ្សេងទៀតដែលចាំបាច់។

មាត្រា ១៦.-

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យ[illegible] ឬសំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ។

ជំពូកទី៤
ធនធាន

មាត្រា ១៧.-

ជំរឿនកសិកម្ម ឆ្នាំ២០១៣ មានប្រភពធនធានដូចតទៅ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា
- ប្រភពធនធានស្របច្បាប់ផ្សេងៗ។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា ១៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែធ្នូ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១៩*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៦៨២,៤៥ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៥៥គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៤៤៨ គ្រួសារ លើ ៦១៨ ក្បាលដី នៅស្រុកដំណាក់ចង្អើរ ខេត្តកែប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ១២៤សណ/ខក ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ៦៨២,៩៥ ហិកតា(ប្រាំមួយរយប៉ែតសិបពីរហិកតា និងសែសិបប្រាំអា) ចេញពីគម្របព្រៃឈើឆ្នាំ២០០២ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៥៥ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់និងដាំដុះជាក់ស្តែងស្ថិតនៅស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលមានទំហំ និងចំនួនគ្រួសារស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម៖

- ផ្ទៃដីទំហំ១២២,៤០ ហិកតា (មួយរយម្ភៃពីរ ហិកតា និងសែសិបអា) កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ **អន្លង់ស ឃុំពងទឹក**
- ផ្ទៃដីទំហំ៤៥៨,៥៦ ហិកតា (បួនរយហាសិបប្រាំបី ហិកតា និងហាសិបប្រាំមួយអា) កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ**ចំការបី ឃុំពងទឹក**
- ផ្ទៃដីទំហំ៨០,៩៥ ហិកតា (ប៉ែតសិប ហិកតា និងសែសិបប្រាំអា) កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ **ភ្នំលាវ ឃុំពងទឹក**

- ផ្ទៃដីទំហំ២១,០៤ ហិកតា (ម្ភៃមួយ ហិកតា និងបួនអា) កាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិអង្កោល ឃុំអង្កោល

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ឧបសម្ព័ន្ធទី២ ឧបសម្ព័ន្ធទី៣ និងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

មាត្រា២.

ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែប ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៤៥៥ គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅខេត្តកែប ស្រុកដំណាក់ចង្អើរ នៅក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥០គ្រួសារ នៅភូមិអន្ទង់ស ឃុំពងទឹក

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៨គ្រួសារ នៅភូមិចំការបី ឃុំពងទឹក

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ១២៦ គ្រួសារនៅភូមិភ្នំលាវ ឃុំពងទឹក-

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦៤ គ្រួសារ នៅភូមិអង្កោលឃុំអង្កោល

មាត្រា ៣ ..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ៦១៨ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៤៤៨ គ្រួសារ ស្ថិតនៅស្រុកដំណាក់ចង្អើរ ខេត្តកែបដូចខាងក្រោម ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន៦៥ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៥០ គ្រួសារ នៅភូមិអន្ទង់ស ឃុំពងទឹក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន លើក្បាលដីចំនួន ២៨១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២០៨ គ្រួសារ នៅភូមិចំការបី ឃុំពងទឹក
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៧២ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១២៦ គ្រួសារ នៅភូមិភ្នំលាវ ឃុំពងទឹក-
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១០០ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៦៤ គ្រួសារ នៅភូមិអង្កោលឃុំអង្កោល

មាត្រា ៤ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែបត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៥ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ (

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំ ៦៨២ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ២០០៥ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មសិទ្ធិ ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នូវផ្ទៃដីទំហំ ៦៨២ ហិកតា ចំនួន ៤៥៥ គ្រួសារ នៅភូមិចំការបី ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប



ID	E	N	ID	E	N
1	435006	1174750	35	432764	1174200
2	434957	1173960	36	432830	1174410
3	434711	1173750	37	432916	1174540
4	434119	1173560	38	432583	1174660
5	434286	1172660	39	432336	1174390
6	434221	1172210	40	432259	1174320
7	434059	1171700	41	432195	1174420
8	434372	1171440	42	432631	1174970
9	433481	1170670	43	432920	1175210
10	433377	1170380	44	432978	1175210
11	433226	1170150	45	433149	1175210
12	432990	1170200	46	433274	1175280
13	431577	1170670	47	433369	1175300
14	431323	1170120	48	433549	1175250
15	430865	1169360	49	433836	1175110
16	430580	1169430	50	434365	1175150
17	430806	1169840	51	434233	1174840
18	430536	1169880	52	435006	1174750
19	430413	1170010	53	433409	1171860
20	430523	1170190	54	433753	1171490
21	430879	1170160	55	433918	1171580
22	431056	1170420	56	433663	1171930
23	431526	1170940	57	433539	1172220
24	432335	1171740	58	433393	1172460
25	432481	1171970	59	433500	1172940
26	432441	1172080	60	433422	1173200
27	432313	1172630	61	433226	1173690
28	432252	1172700	62	433063	1174210
29	432255	1172790	63	432722	1174000
30	432365	1172850	64	432319	1173780
31	432157	1173330	65	432479	1173170
32	432130	1173650	66	432769	1172710
33	432165	1173790	67	433020	1172080
34	432631	1174230	68	433409	1171860

ឧបសម្ព័ន្ធ ២

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...២៦៧...ចុះថ្ងៃទី០៥..ខែ..ធ្នូ....ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំ ៦៨២ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ២០០ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មសិទ្ធិ ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នូវផ្ទៃដីទំហំ ៦៨២ ហិកតា ចំនួន ៤៥៥ គ្រួសារ នៅភូមិអន្ទង់ស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប



តារាងនិយាមកាចំណុចព្រំដី

Projection: UTM, Zone 48N, Datum WGS 84

ឧបករណ៍វាស់វែង: GPSMAP 62s

ID	E	N	ID	E	N
1	428199	1165560	43	430148	1168740
2	427870	1165570	44	430183	1168780
3	427901	1165700	45	430261	1168730
4	428124	1166110	46	430354	1168870
5	427997	1166090	47	430297	1168930
6	427928	1166320	48	430364	1169140
7	428089	1166440	49	430331	1169260
8	428126	1166540	50	430579	1169430
9	428490	1166490	51	430871	1169360
10	428519	1166640	52	430451	1168720
11	428227	1166670	53	429714	1167720
12	428206	1166840	54	429541	1167440
13	428291	1166980	55	429618	1167460
14	428392	1166940	56	429975	1167440
15	428522	1167080	57	430054	1167470
16	428323	1167170	58	430092	1167600
17	428312	1167440	59	430227	1167550
18	428525	1167170	60	430197	1167300
19	428654	1167330	61	430601	1167250
20	428176	1167700	62	430575	1166990
21	428178	1167750	63	430187	1167040
22	428507	1167670	64	430169	1166890
23	428818	1167420	65	430057	1166900
24	428915	1167090	66	430082	1167100
25	429234	1167270	67	429816	1167150
26	429176	1167380	68	429712	1167300
27	429179	1167620	69	429530	1167280
28	429275	1167760	70	429532	1167220
29	429250	1167970	71	429590	1167110
30	429400	1168010	72	429532	1167030
31	429480	1168080	73	429470	1167140
32	429467	1168200	74	429243	1167100
33	429555	1168220	75	429259	1166930
34	429647	1168160	76	429076	1166870
35	429632	1168100	77	429502	1166850
36	429697	1168030	78	429634	1166560
37	429954	1168330	79	429502	1166500
38	429862	1168460	80	428791	1166630
39	429892	1168490	81	428766	1166520
40	430039	1168390	82	428627	1166380
41	430134	1168420	83	428440	1166110
42	430171	1168610	84	428318	1165870
			85	428199	1165560

ឧបសម្ព័ន្ធ ៣

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.........ចុះថ្ងៃទី.......ខែ.......ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំ ៦៨២ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មសិទ្ធិ ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នូវផ្ទៃដីទំហំ ៦៨២ ហិកតា ចំនួន ៤៥៥ គ្រួសារ នៅភូមិអន្ទង់ស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប



តារាងនិយាមកាចំណុចព្រំដី

Projection: UTM, Zone 48N, Datum WGS 84

ឧបករណ៍វាស់វែង: GPSMAP 62s

ID	X	Y	ID	X	Y
1	429223	1160580	65	429155	1161070
2	429194	1160560	66	429105	1161150
3	428885	1160870	67	429128	1161170
4	428837	1160880	68	429181	1161120
5	428777	1160950	69	429226	1161100
6	428814	1160960	70	429256	1161100
7	428819	1160970	71	429309	1161080
8	428914	1160890	72	429348	1161090
9	428955	1160830	73	429395	1161130
10	429064	1160760	74	429413	1161230
11	429223	1160580	75	429399	1161250
12	428906	1162180	76	429377	1161240
13	428908	1162180	77	429326	1161330
14	429102	1162190	78	429290	1161330
15	429186	1162180	79	429181	1161340
16	429352	1162120	80	429213	1161510
17	429473	1162070	81	429245	1161850
18	429540	1162040	82	429291	1161930
19	429550	1161960	83	429192	1161920
20	429533	1161750	84	429112	1161920
21	429652	1161720	85	428984	1161940
22	429672	1161530	86	428956	1161870
23	429525	1161160	87	428882	1161890
24	429466	1161040	88	428791	1162030
25	429472	1161000	89	428712	1161970
26	429446	1160980	90	428815	1161800
27	429421	1160880	91	428911	1161640
28	429391	1160860	92	429008	1161630
29	429357	1160790	93	429031	1161580
30	429358	1160740	94	429036	1161510
31	429354	1160660	95	429009	1161490
32	429351	1160660	96	428967	1161420
33	429377	1160640	97	428883	1161460
34	429471	1160620	98	428880	1161440
35	429500	1160610	99	428780	1161420
36	429517	1160610	100	428744	1161410
37	429526	1160610	101	428731	1161370
38	429577	1160600	102	428688	1161260
39	429608	1160580	103	428692	1161150
40	429619	1160560	104	428691	1161150
41	429641	1160530	105	428577	1161120
42	429658	1160500	106	428518	1161180
43	429635	1160460	107	428455	1161350
44	429634	1160460	108	428439	1161400
45	429633	1160460	109	428426	1161540
46	429628	1160450	110	428406	1161670
47	429603	1160430	111	428386	1161720
48	429573	1160420	112	428380	1161770
49	429537	1160420	113	428386	1161820
50	429428	1160430	114	428400	1161920
51	429345	1160480	115	428402	1161960
52	429210	1160560	116	428410	1162020
53	429265	1160590	117	428431	1162040
54	429275	1160620	118	428449	1162080
55	429217	1160670	119	428461	1162130
56	429172	1160710	120	428493	1162160
57	429138	1160750	121	428513	1162200
58	429118	1160770	122	428538	1162250
59	429134	1160790	123	428566	1162300
60	429165	1160840	124	428726	1162310
61	429182	1160850	125	428917	1162300
62	429184	1160860	126	428910	1162210
63	429091	1160980	127	428909	1162200
64	429112	1161040	128	428908	1162190
			129	428906	1162180

ឧបសម្ព័ន្ធ (៤

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ[illegible]ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១២ ស្តីពីការកាត់ដីទំហំ ៦៨២ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មសិទ្ធិ ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នូវផ្ទៃដីទំហំ ៦៨២ ហិកតា ចំនួន ៤៥៥ គ្រួសារ នៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប



តារាងនិយាមកាចំណុចព្រំដី

Projection:UTM, Zone 48N, Datum WGS 84

ឧបករណ៍វាស់វែង:GPSMAP 62s

ID	E	N	ID	E	N
1	433476	1156680	63	432826	1156370
2	433534	1156610	64	432838	1156460
3	433547	1156580	65	432844	1156490
4	433591	1156520	66	432879	1156550
5	433573	1156520	67	432926	1156610
6	433560	1156470	68	433007	1156660
7	433541	1156420	69	433080	1156710
8	433526	1156340	70	433139	1156740
9	433492	1156290	71	433303	1156770
10	433434	1156180	72	433356	1156790
11	433395	1156140	73	433476	1156680
12	433336	1156050	74	433205	1156620
13	433286	1155990	75	433128	1156530
14	433226	1155990	76	433080	1156530
15	433209	1155980	77	433038	1156550
16	433217	1155970	78	433006	1156550
17	433259	1155940	79	432979	1156550
18	433281	1155920	80	432955	1156550
19	433302	1155820	81	432933	1156550
20	433301	1155810	82	432901	1156530
21	433316	1155800	83	432894	1156500
22	433326	1155770	84	432914	1156460
23	433343	1155770	85	432932	1156430
24	433342	1155750	86	432948	1156370
25	433349	1155690	87	432964	1156340
26	433352	1155670	88	432964	1156340
27	433358	1155640	89	432974	1156300
28	433339	1155580	90	433023	1156240
29	433320	1155560	91	433114	1156110
30	433315	1155540	92	433105	1156040
31	433303	1155540	93	433110	1155970
32	433280	1155520	94	433196	1156150
33	433270	1155510	95	433290	1156300
34	433224	1155490	96	433418	1156350
35	433200	1155490	97	433477	1156390
36	433170	1155490	98	433461	1156410
37	433150	1155500	99	433456	1156430
38	433098	1155550	100	433447	1156450
39	433077	1155580	101	433384	1156540
40	433048	1155630	102	433357	1156590
41	433038	1155680	103	433327	1156620
42	433052	1155740	104	433309	1156640
43	433054	1155760	105	433274	1156660
44	433069	1155820	106	433258	1156680
45	433068	1155830	107	433197	1156670
46	433078	1155860	108	433197	1156670
47	433070	1155870	109	433196	1156670
48	433079	1155880	110	433205	1156620
49	433089	1155870	111	433186	1155880
50	433114	1155910	112	433127	1155730
51	433115	1155910	113	433111	1155670
52	433122	1155920	114	433118	1155620
53	433112	1155920	115	433206	1155540
54	433112	1155940	116	433252	1155540
55	433112	1155950	117	433313	1155570
56	433124	1155950	118	433311	1155650
57	433111	1155950	119	433286	1155710
58	433075	1155960	120	433262	1155770
59	432982	1156080	121	433259	1155800
60	432855	1156270	122	433254	1155880
61	432848	1156280	123	433230	1155900
62	432832	1156320	124	433210	1155900
			125	433186	1155880

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៤២៨..អនក្រ-បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៨ ០០០ ០០០ ០០០រៀល(ប្រាំបីពាន់លានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦៥(ឧបត្ថម្ភកធននិងជំនួយសង្គម) របស់ក្រសួងសុខាភិបាល សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទិញឱសថបន្ថែមសម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០១២។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២២៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ១.៨៥៤,៧២៩៩ ហិកតា នៅស្រុកអណ្តូងមាស និងស្រុកបរកែវ ខេត្តរតនគិរី ពីក្រុមហ៊ុន ហេង ប្រាឌ័រ និងក្រុមហ៊ុន ខាសនា អ៊ិនវេសមេន ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងរក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសំណើសុំផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១៧ លេខ៦១៨ និងលេខ៦១៩/១២ លអខ ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគីរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១.៨៥៤,៣២៩៩ ហិកតា ដែលក្នុងនោះផ្ទៃដីទំហំ ៥,០៧៦៦ ហិកតា ពីក្រុមហ៊ុន ហោង ប្រាឌ័រ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងផ្ទៃដីទំហំ ១.៨៤៩,២៥៣៣ ហិកតា ពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៩១០,២២៩៥ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលស្ថិតនៅស្រុកបរកែវ និងស្រុកអណ្តូងមាស ក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៥៥១,៨៦៧៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន ដើម្បីធ្វើប្រទានកម្មនូវផ្ទៃដីទំហំ ៤៧៦,១៣៦៨ ហិកតា ជូនជាកម្មសិទ្ធិដល់ប្រជាពលរដ្ឋ និងផ្ទៃដីទំហំ ៧៥,៧៣០៧ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលស្ថិតនៅភូមិទៀន ឃុំកិះចុង ស្រុកបរកែវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ
- ផ្ទៃដីទំហំ ៦៨,៩៣៥០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន ដើម្បីធ្វើប្រទានកម្មនូវផ្ទៃដីទំហំ ៥៣,១៧២៦ ហិកតា ជូនជាកម្មសិទ្ធិដល់

ប្រជាពលរដ្ឋ និងផ្ទៃដីទំហំ ១៥,៧៦២៤ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលស្ថិតនៅភូមិប៉ាអ ឃុំកិះចុង ស្រុកបរកែវ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ

- ផ្ទៃដីទំហំសរុប ១.២៣៣,៥២៧៤ ហិកតា ដែលក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន ទំហំ ១.២២៨,៤៥០៨ ហិកតា និងពីក្រុមហ៊ុន ហេង ប្រាឌ័រ ទំហំ ៥,០៧៦៦ ហិកតា ដើម្បីធ្វើប្រទានកម្មនូវផ្ទៃដីទំហំ ៩១៤,៧៩១០ ហិកតា ជូនជាកម្មសិទ្ធិដល់ប្រជាពលរដ្ឋ ១៩៣ គ្រួសារ និងផ្ទៃដីទំហំ ៣១៨,៧៣៦៤ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលស្ថិតនៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកអណ្តូងមាស តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣០២ គ្រួសារ ដែលស្ថិតនៅស្រុកបរកែវ និងស្រុកអណ្តូងមាស ក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៩២ គ្រួសារ នៅភូមិទៀន ឃុំកិះចុង ស្រុកបរកែវ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៧ គ្រួសារ នៅភូមិប៉ាអ ឃុំកិះចុង ស្រុកបរកែវ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៣ គ្រួសារ នៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកអណ្តូងមាស

មាត្រា ៣ ..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ចំនួន ៥២១ ក្បាលដី ក្នុងនោះផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៨៦ គ្រួសារ លើ ៥២០ ក្បាលដី និងសិទ្ធិជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (សាលារៀន) ដែលនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើ ១៣៦ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ៩២ គ្រួសារ នៅភូមិទៀន ឃុំកិះចុង ស្រុកបរកែវ ។
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើ ២២ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៦ គ្រួសារ នៅភូមិប៉ាអ ឃុំកិះចុង ស្រុកបរកែវ ។
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើ ៣៦២ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១៧៨ គ្រួសារ និងសិទ្ធិជាកម្មសិទ្ធិជាសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (សាលារៀន) នៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកអណ្តូងមាស ។

មាត្រា ៤.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :២៣០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១:ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៨ ០៩០ ៦០០ ០០០រៀល(ប្រាំបីពាន់កៅសិបលានប្រាំមួយរយពាន់រៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២:ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនអង្គភាពកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់សម្រាប់:

១	ជួសជុលឧទ្ធម្ភាគចក្រ MI-8 (០២គ្រឿង) ជំហានទី៣	ចំនួន	៤ ២២៥ ២០០ ០០០រៀល
២	ប្រេងឥន្ធនៈគ្រប់ប្រភេទ	ចំនួន	៣ ៥០០ ០០០ ០០០រៀល
៣	ពិនិត្យបច្ចេកទេសឧទ្ធម្ភាគចក្រ ECUREUIL XU-007, XU-015, XU-018	ចំនួន	៣៦៥ ៤០០ ០០០រៀល

មាត្រា៣:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..៥៣១..អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៧១៤ ០០០ ០០០រៀល(ប្រាំពីររយដប់បួនលានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦០(ការទិញ) ជូនក្រសួងការពារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយទូទាត់សងថ្លៃប្រេងឥន្ធនៈជំហានទី២ បម្រើសកម្មភាពវាស់វែងដីធ្លីផ្ដល់កម្មសិទ្ធិជូនប្រជាពលរដ្ឋរបស់យុវជនស្ម័គ្រចិត្តសម្ដេចតេជោនាយករដ្ឋមន្ត្រី។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៣៥៦ ០០០ ០០០រៀល(បីរយហាសិបប្រាំមួយលានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥(ឧបត្ថម្ភកធន និងជំនួយសង្គម) ជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយបង់វិភាគទានជូនអង្គការសហប្រជាជាតិផ្នែកបេសកកម្មរក្សាសន្តិភាពនិងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១០ ០០០ ០០០ ០០០រៀល(ដប់ពាន់លានរៀលគត់) ពីជំពូក ០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥(ឧបត្ថម្ភកធននិងជំនួយសង្គម)-ថវិកាកម្មវិធី ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តការចុះបញ្ជីដីធ្លីបន្ថែមចំនួន១៨០ ០០០ក្បាលដី។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ខែ ៩ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣៤. អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ៤៤៨ ហិកតា ដែលក្នុងនោះ (១). កាត់ចេញពីឧទ្យានជាតិកែប នៃព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, (២) ពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ នូវទំហំ ៤២៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៤៥ គ្រួសារ និងទំហំ ២១ ហិកតា រក្សាទុកសម្រាប់ជាដីឯកជនរបស់រដ្ឋ សម្រាប់សម្បទានគោលដៅសង្គមកិច្ច និងផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ២៣៣ គ្រួសារ លើ៤៣៦ ក្បាលដី នៅក្រុងកែប ខេត្តកែប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១២/១០២៣ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ១២៣សណ/ខក ចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ ២០១២ របស់គណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋខេត្តកែប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ៤៩៨ (បួនរយសែសិបប្រាំបី) ហិកតា ដែលក្នុងនោះ (១). ផ្ទៃដីទំហំ ១៧១ (មួយរយចិតសិបមួយ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ត្រង់មាត្រា ២ ចំណុច ១ លេខរៀងទី ៣ (២). ផ្ទៃដីទំហំ ២៧៧ ហិកតាពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីទំហំ ៤២៧ (បួនរយម្ភៃប្រាំពីរ) ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់និងដាំដុះជាក់ស្តែង និងទំហំ ២១ (ម្ភៃមួយ)ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ចនៅក្រុងកែប ខេត្តកែប ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិ សង្កាត់ ដូចខាងក្រោម ៖

- ផ្ទៃដីសរុបទំហំ ៣២៨ (បីរយម្ភៃប្រាំបី)ហិកតា ក្នុងនោះ (១) ទំហំ ៥១ (ហាសិបមួយ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប (២)ទំហំ ២៧៧ (ពីររយចិតសិបប្រាំពីរ) ហិកតា កាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣២២ (បីរយម្ភៃពីរ) ហិកតា សម្រាប់ប្រទានកម្ម

ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០៦ (ប្រាំមួយ)ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ច នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ

- ផ្ទៃដីសរុបទំហំ ៤៥ (សែសិបប្រាំ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣០ (សាមសិប) ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនិងទំហំ ១៥ (ដប់ប្រាំ) ហិកតា រក្សាទុកជាដីឯកជនរបស់រដ្ឋសម្រាប់សម្បទានគោលដៅសង្គមកិច្ច នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ

- ផ្ទៃដីទំហំ ៧៥ (ចិតសិបប្រាំ) ហិកតា កាត់ចេញពីឧទ្យានជាតិកែប ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកែបក្រសាំង សង្កាត់កែប

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

មាត្រា២.

ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែប ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៤៥ គ្រួសារដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅខេត្តកែប ក្រុងកែប នៅក្នុងភូមិ សង្កាត់ដូចខាងក្រោម ៖

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៨០ គ្រួសារ នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥១ គ្រួសារ នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ

-សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១១៤ គ្រួសារ នៅភូមិកែបក្រសាំង សង្កាត់កែប

មាត្រា ៣ ..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ៤៣៦ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ២៣៣ គ្រួសារ ស្ថិតនៅក្រុងកែប ខេត្តកែបដូចខាងក្រោម ៖

- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៨៥ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៧៥គ្រួសារ នៅភូមិតំណាក់ចង្អើរ សង្កាត់ព្រៃធំ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ៨០ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ៥១គ្រួសារ នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ
- ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជនលើក្បាលដីចំនួន ១៧១ ក្បាលដីជូនប្រជាពលរដ្ឋចំនួន ១០៧ គ្រួសារ នៅភូមិកែបក្រសាំង សង្កាត់កែប

មាត្រា ៤ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកែបត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៥ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៣៥ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ជូនក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា:លានរៀល

ជំពូក	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ	និយ័តកម្ម		ឥណទានថ្មី
			កើន	ថយ	
២១	**និយ័តកម្មចេញ**				
	៩៩- ឥណទានមិនទាន់បែងចែក អចលកម្មរូបី	៣១០ ០០០		២១៤ ០០០	៩៦ ០០០
២១	**និយ័តកម្មចូល**				
	១៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ អចលកម្មរូបី	១៥ ០០០	៤ ០០០		១៩ ០០០
	២០- ក្រសួងអភិវឌ្ឍន៍ជនបទ អចលកម្មរូបី	១០០ ០០០	៥០ ០០០		១៥០ ០០០
	២៥- ក្រសួងសាធារណការ និងដឹកជញ្ជូន អចលកម្មរូបី	២០៥ ០០០	១២០ ០០០		៣២៥ ០០០
	២៩- ក្រសួងធនធានទឹក និងឧតុនិយម អចលកម្មរូបី	៩០ ០០០	៤០ ០០០		១៣០ ០០០

ប្រការ២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០៩៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ :

ត្រូវបានបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ១.៤២៧ កន្លែង (មួយពាន់បួនរយម្ភៃប្រាំពីរ) ដល់ក្រសួងមហាផ្ទៃ សម្រាប់តម្រូវការចាំបាច់នៃការងារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

មាត្រា ២ :

ក្របខ័ណ្ឌបំពេញថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិ ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ ។

មាត្រា ៣ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៩៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំង និងដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា ១ : តែងតាំងលោក **ឆួន គិរម្យ** ជាប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃក្រសួងអភិវឌ្ឍន៍ជនបទ ជំនួសឯកឧត្តម **ឯក ឆា** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍។

មាត្រា ២ : ដំឡើងឋានន្តរស័ក្តិ ជូនលោក **ឆួន គិរម្យ** ពីអនុមន្ត្រី ថ្នាក់លេខ ៨ ទៅវរមន្ត្រី ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៧១០០.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចលោក **ឱម ច័ន្ទតារា** ពីប្រធាននាយកដ្ឋានព័ត៌មានទៅជាប្រធាននាយកដ្ឋានសារគមនាគមន៍ នៃអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ជំនួសលោក **សៅ ស៊ីសុវណ្ណា** ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ជា សុផា** អនុមន្ត្រីថ្នាក់លេខ ១០ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានព័ត៌មាន នៃអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២១០១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ម៉ង់ ឧបសិទ្ធិ** ដែលបានស្ម័គ្រចិត្តចូលរួមក្នុងយុទ្ធនាការចុះវាស់វែងដីធ្លី និងធ្វើកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស កន្លងមក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ធ្នូ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១០៧ .អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមាននាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ	**ម៉ៅ**	**សុខា**	អត្តលេខ ០០៨៥០៥	ជំនួយការ ឯកឧត្តម នាយក មន្ទីរពេទ្យព្រះកេតុមាលា
២-វរសេនីយ៍ទោ	**មុី**	**ធរៈជេដ្ឋ**	អត្តលេខ ០២៥០២៧	នាយ លេខាធិការដ្ឋាន អគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស
៣-វរសេនីយ៍ទោ	**កុសល**	**សុវណ្ណនន្ទា**	អត្តលេខ ០១៣១២៤	នាយ ការិយាល័យគណនេយ្យ នាយកដ្ឋានហិរញ្ញវត្ថុ អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ
៤-វរសេនីយ៍ទោ	**អុី**	**រតនៈវិសេស**	អត្តលេខ ០១១២២៩	លេខា ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា
៥-វរសេនីយ៍ទោ	**ផល**	**សារឿន**	អត្តលេខ ០០៨៤៨២	ជំនួយការ ឯកឧត្តម កៅ ទ្រី អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៦-វរសេនីយ៍ទោ **ម៉ុក ឈឹម** អត្តលេខ ០៣០៧៥៥ នាយការិយាល័យភស្តុភារ
អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
៧-វរសេនីយ៍ទោ **កែវ គឹមសាន** អត្តលេខ ០៤២៩៨៤ នាយការិយាល័យព័ត៌មានវិទ្យា
អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
៨-វរសេនីយ៍ទោ **ហ៊ិន សាមល់** អត្តលេខ ០១៩៩០៨ នាយការិយាល័យពិធីការ និងបកប្រែ
នាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
៩-វរសេនីយ៍ទោ **ស៊ុន គឹមលី** អត្តលេខ ០១៦៨៤៨ ជំនួយការ នាយក
នាយកដ្ឋានអធិការកិច្ច
១០-វរសេនីយ៍ទោ **ចាន់ ម៉ុនណារឿន** អត្តលេខ ០៤៨១៧៣ នាយផ្នែកប្រចាំទិសមុំបី ប្រាសាទ
ព្រះវិហារ នាយកដ្ឋានបុគ្គលិក
១១-វរសេនីយ៍ទោ **មុំ ម៉ុនថា** អត្តលេខ ០១៤១១៥ ជំនួយការ ឯកឧត្តម **នាង ផង**
១២-វរសេនីយ៍ទោ **ម៉ែន សោភា** អត្តលេខ ០០១៦៦៦ ជំនួយការ ឯកឧត្តម **ផន ណារ៉ា**
អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស
១៣-វរសេនីយ៍ទោ **អ៊ុច ឧត្តរី** អត្តលេខ ០៦៧៩៥១ នាយ កងគ្រឿងចក្រ១៧៨
នាយកដ្ឋានវិស្វកម្ម អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ
១៤-វរសេនីយ៍ទោ **គង់ តិរៈ** អត្តលេខ ០៤៨៣៤០ នាយ ការិយាល័យពិសោធន៍ភាសា
បណ្ណាល័យ មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមនិងភាសា សាកលវិទ្យាល័យការពារជាតិ
១៥-វរសេនីយ៍ទោ **ជុង សុខឆាយ** អត្តលេខ ០៧៧៥៨១ នាយ ការិយាល័យទំនាក់ទំនង
សាធារណៈ និងអន្តរជាតិ នាយកដ្ឋានរដ្ឋបាល ភស្តុភារ បច្ចេកទេស អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិ
ទប់ស្កាត់ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៦-វរសេនីយ៍ទោ **យ័ន្ត ប្រុកប** អត្តលេខ ០៣២៣៦៦ នាយការិយាល័យវិភាគសារធាតុគីមី
វិទ្យាស្ថានស្រាវជ្រាវនិងពិសោធន៍សារធាតុអាវុធគីមី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី
នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៧-វរសេនីយ៍ទោ **ស៊ុំ ច័ន្ទរិទ្ធ** អត្តលេខ ០២៣១០៦ នាយការិយាល័យព័ត៌មាន
នាយកដ្ឋានព័ត៌មាននិងគ្រប់គ្រងស្ថានីយ៍ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី
នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
១៨-វរសេនីយ៍ទោ **ឈុន ចិន្តា** អត្តលេខ ០១៤២៧៤ នាយ ការិយាល័យគោលរបប
នាយកដ្ឋានសោធននិវត្តន៍ អគ្គនាយកដ្ឋានយោធសេវា
១៩-វរសេនីយ៍ទោ **សៅ សុវណ្ណី** អត្តលេខ ០៥៨៨៥៧ នាយការិយាល័យពិធីការ និងបកប្រែ
នាយកដ្ឋានរដ្ឋបាល ភស្តុភារ បច្ចេកទេស អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់ អាវុធគីមី នុយក្លេអ៊ែរ
ជីវសាស្ត្រ និងវិទ្យុសកម្ម
២០-វរសេនីយ៍ទោ **រ័ត្ន សារុន** អត្តលេខ ០០៨៤៨៦ នាយ លេខាធិការដ្ឋាន
ស្ថាប័នអយ្យការយោធា
២១-វរសេនីយ៍ទោ **អ៊ូច សុផាន់ណា** អត្តលេខ ០០១៧៦៧ នាយ ការិយាល័យឱសថ
នាយកដ្ឋានសុខាភិបាល
២២-វរសេនីយ៍ទោ **គីម សុចិត្រា** អត្តលេខ ០១៣៦៩៦ នាយ លេខាធិការដ្ឋាន
នាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

២៣-វរសេនីយ៍ទោ **ឡាយ សុខវណ្ណា** អត្តលេខ ០១២២០៦ នាយ លេខាធិការដ្ឋាន នាយកដ្ឋានភូមិសាស្ត្រ

២៤-វរសេនីយ៍ទោ **ឡាច ចំណាប់** អត្តលេខ ០០១៤២៣ នាយផ្នែកប្រចាំទិសប្រាសាទតាមាន់ នាយកដ្ឋានបុគ្គលិក

២៥-វរសេនីយ៍ទោ **ឆ្ងូរ ចិរៈ** អត្តលេខ ០៣១៧៩៩ នាយការិយាល័យចៅក្រមជំនុំជំរះ ស្ថាប័នតុលាការយោធា

២៦-វរសេនីយ៍ទោ **អ៊ុច ថាច** អត្តលេខ ០២៥៨៨៣ នាយលេខាធិការដ្ឋាន មហាវិទ្យាល័យ ព័ត៌មានវិទ្យា ភស្តុភារ ហិរញ្ញវត្ថុ សាកលវិទ្យាល័យការពារជាតិ

២៧-វរសេនីយ៍ទោ **ហ៊ួន រ៉ាវី** អត្តលេខ ០៦៣៧៨១ ជំនួយការ ឯកឧត្តម នាង ផែន អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា

២៨-វរសេនីយ៍ទោ **ស៊ុំ ចិន្តា** អត្តលេខ ០១៩៩០២ ជំនួយការ ឯកឧត្តម អ៊ុន ផែន អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

២៩-វរសេនីយ៍ទោ **ឡេង ស្រ៊ុន** អត្តលេខ ០១០៩៩៣ ជំនួយការ ឯកឧត្តម ស៊ូ គឹមស៊ុន អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៣០-វរសេនីយ៍ទោ **និយម បុល** អត្តលេខ ០០១៧៦២ ប្រធានសុខាភិបាលប្រចាំទិស១ ស្រអែម អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៣១-វរសេនីយ៍ទោ **ម៉ឹង សត្ថារា** អត្តលេខ ០១៤៣០១ ប្រធានសុខាភិបាលប្រចាំទិស៣ អន្លង់វែង អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៣២-វរសេនីយ៍ទោ **ម៉ក សុផៃ** អត្តលេខ ០០១៧៥៣ ប្រធានសុខាភិបាលប្រចាំទិស២ ឧត្តរមានជ័យ អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៣៣-វរសេនីយ៍ទោ **សរ សំណាង** អត្តលេខ ០០២១៨៩ ប្រធានសុខាភិបាលប្រចាំទិស យោធភូមិភាគទី៥ អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៣៤-វរសេនីយ៍ទោ **មាស សារ៉េត** អត្តលេខ ០០៩៦១៧ ជំនួយការ ឯកឧត្តម គង់ អៀង

៣៥-វរសេនីយ៍ទោ **ចាន់ ផេង** អត្តលេខ ០០១៧៨៤ ជំនួយការ ឯកឧត្តម គង់ អៀង

៣៦-វរសេនីយ៍ទោ **លឹម អៀង** អត្តលេខ ០៣១៤០២ ជំនួយការ ឯកឧត្តម សុន គឹមសឺន អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៣៧-វរសេនីយ៍ទោ **មុំ សំអាន** អត្តលេខ ១៤៥៤៨២ ជំនួយការ ឯកឧត្តម ហង្ស បូណា អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៣៨-វរសេនីយ៍ទោ **យឹម សម្បត្តិរតនា** អត្តលេខ ០០៨៦០១ ជំនួយការ ឯកឧត្តម អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៣៩-វរសេនីយ៍ទោ **សុត សុភិន** អត្តលេខ ០១១៩៤៩ នាយការិយាល័យវាស់វែង នាយកដ្ឋានភូមិសាស្ត្រ

៤០-វរសេនីយ៍ទោ **ឲុន ម៉ិនធឿន** អត្តលេខ ០១១៤៩៣ ជំនួយការ ឯកឧត្តម ស៊ូ គឹមស៊ុន អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៤១-វរសេនីយ៍ទោ **សុខ ចិន្តា** អត្តលេខ ០០១៥៨៣ ជំនួយការ ឯកឧត្តម ហេង រ៉ាត្នី អគ្គលេខាធិការរង នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

៤២-វរសេនីយ៍ទោ **ខាត់ ថន** អត្តលេខ ០១៣៨៥៦ ជំនួយការ ឯកឧត្តម ស៊ុំ សំណាង អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៤៣-វរសេនីយ៍ទោ **ហេង ពិសិដ្ឋ** អត្តលេខ ០២៤៧៨០ នាយករង មជ្ឈមណ្ឌលហ្វឹកហ្វឺនយន្តសាស្ត្រ វិទ្យាស្ថានបច្ចេកទេស យោធាតេជោ ហ៊ុន សែន អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៤៤-វរសេនីយ៍ទោ **ឆេង យុន** អត្តលេខ ០៤៣២២២ នាយការិយាល័យហ្វឹកហ្វឺន នាយកដ្ឋានភូមិសាស្ត្រ

៤៥-វរសេនីយ៍ទោ **នួន ហេង** អត្តលេខ ០១០៥២៩ ជំនួយការ ឯកឧត្តម ចាយ សាំងយុន

៤៦-វរសេនីយ៍ទោ **ចាន់ ស៊ីថា** អត្តលេខ ០០៨៤២២ នាយការិយាល័យសម្ភារៈ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៤៧-វរសេនីយ៍ទោ **រស់ សំអាត** អត្តលេខ ០១៩៧២៦ នាយការិយាល័យស្រាវជ្រាវបច្ចេកវិទ្យា កងទ័ពជើងអាកាស នាយកដ្ឋានបច្ចេកទេសកងទ័ពជើងអាកាស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៤៨-វរសេនីយ៍ទោ **វ៉ាត ឃឿន** អត្តលេខ ០១៧៧៧២ នាយការិយាល័យគ្រប់គ្រង រោងជាងឃ្លាំង នាយកដ្ឋានបច្ចេកទេសកងទ័ពជើងអាកាស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៥០-វរសេនីយ៍ទោ **កុល រ៉េត** អត្តលេខ ០២៤៧៩៣ នាយការិយាល័យរថក្រោះ រថពាស-ដែក នាយកដ្ឋានយាន្តយន្ត អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៥១-វរសេនីយ៍ទោ **ម៉ិល វ៉េមីស៊ីសុផុន** អត្តលេខ ០៣៧៦២៧ នាយការិយាល័យបច្ចេកទេសផ្ទៃដី នាយកដ្ឋានបច្ចេកទេសកងទ័ពជើងអាកាស អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៥២-វរសេនីយ៍ទោ **តោគ វ៉ាន់ថន** អត្តលេខ ០២១៧៥៥ ជំនួយការ ឯកឧត្តម ប្រាក់ សុខុន

៥៣-វរសេនីយ៍ទោ **អ៊ុំ សុវណ្ណារ៉ា** អត្តលេខ ០១៣៧០៥ ជំនួយការ ឯកឧត្តម យុន រ៉ុង

៥៤-វរសេនីយ៍ទោ **អ៊ី ពុទ្ធី** អត្តលេខ ០១៣៨៤០ នាយផ្នែកប្រចាំទិសយោធភូមិភាគទី៤ នាយកដ្ឋានបុគ្គលិក

៥៥-វរសេនីយ៍ទោ **លី ស៊ាងហ៊ាន់** អត្តលេខ ០៣៧៦៤៦ នាយ ការិយាល័យរថយន្ត-ម៉ាស៊ីន នាយកដ្ឋានយានយន្ត អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

៥៦-វរសេនីយ៍ទោ **មាស រតនៈសោភ័ណ** អត្តលេខ ០៤២៩៦៧ នាយករង នាយកដ្ឋានសោធននិវត្តន៍ អគ្គនាយកដ្ឋានយោធសេវា

មាត្រា២ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេ-បញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ២១០៣.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ ៖ ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជាសិក្ខាកាម ដែលបានបញ្ចប់វគ្គសិក្សានៅសាលាក្រៅប្រទេស ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ	**ជាតិ**	**ប៉ូលីន**	អត្តលេខ ០២៥៦៦៤	វគ្គយុទ្ធសាស្ត្រការពារជាតិ សាធារណរដ្ឋបារាំង
២-វរសេនីយ៍ទោ	**សំរិទ្ធ**	**សារិទ្ធ**	អត្តលេខ ០២៧០៣២	វគ្គយុទ្ធសាស្ត្រនិងការពារជាតិ សាធារណរដ្ឋប្រជាមានិតចិន
៣-វរសេនីយ៍ទោ	**ឌី**	**លីផុន**	អត្តលេខ ០១៨២០៥	វគ្គបញ្ជាការសេនាធិការកងទ័ពជើងគោក សាធារណរដ្ឋប្រជាមានិតចិន
៤-វរសេនីយ៍ទោ	**ញ៉ឹម**	**ប៊ុនី**	អត្តលេខ ០២៥៧២១	វគ្គបញ្ជាការសេនាធិការ ប្រទេសជប៉ុន

៥-វរសេនីយ៍ទោ **នៅ ស៊ីណា** អត្តលេខ ០១៧៤០១ វគ្គបញ្ញាការសេនាធិការ សាធារណរដ្ឋសង្គមនិយមវៀតណាម

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧១០៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៤រូប ដែលមានស្នាដៃល្អ និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយសាងសង់អគារសម្ភព ចំនួន០១ខ្នង នៅមណ្ឌលសុខភាពអូរច្រា ខេត្តប៉ៃលិន មានទំហំ ៨ម៉ែត្រ គុណនឹង ១៧ម៉ែត្រ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

-លោកវេជ្ជបណ្ឌិត	**សេង រ៉ៃ**	ប្រធានមន្ទីរសុខាភិបាលខេត្តប៉ៃលិន

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១-លោកធម្មបណ្ឌិត	**ហេង មុណីចិន្តា**	នាយកអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍
២-លោក	**ចាន់ បូរិន្ទ**	អធិការកម្មវិធីអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍
៣-លោក	**ឈុំ ពោល**	ប្រធានសាខាប៉ៃលិន អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១០៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនមន្ត្រីរាជការ ចំនួន០២រូប ដែលមានស្នាដៃល្អចូលរួមចំណែកក្នុងការសាងសង់អគារសម្ភព ចំនួន០១ខ្នង នៅមណ្ឌលសុខភាពអូរច្រា ខេត្តប៉ៃលិន មានទំហំ៨ម៉ែត្រ គុណនឹង ១៧ម៉ែត្រ ដូចមាននាយនាមខាងក្រោម ៖

១-លោកវេជ្ជបណ្ឌិត **ផាម់ ស៊ូទិចិត្រ** ប្រធានមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន
២-លោកគ្រូពេទ្យ **ហាក់ ឃ៉ិន** ប្រធានមណ្ឌលសុខភាពអូរច្រា

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]១០៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **កែវ ស៊ីវន** អគ្គនាយកនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានស្នាដៃល្អក្នុងការខិតខំបំពេញភារកិច្ចលើវិស័យអាកាសចរស៊ីវិល ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ...១០៣៥... អនុក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់គ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន៥៥រូប ដែលមានស្នាដៃល្អក្នុងការខិតខំបំពេញភារកិច្ចលើវិស័យអាកាសចរស៊ីវិល ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-លោក	មួច	រិទ្ធិ	អគ្គនាយករង
២-លោក	ម៉ាត់	សុទ្ធិ	ប្រធាននាយកដ្ឋានស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍
៣-លោក	ម៉ក់	សំអុល	ប្រធាននាយកដ្ឋានត្រួតពិនិត្យសន្តិសុខ
៤-លោក	ឃឹម	ប៊ុណ្ណា	ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស
៥-លោក	ម៉ឺច	សត្យា	ប្រធាននាយកដ្ឋានផែនការយុទ្ធសាស្ត្រនិងគោលនយោបាយ
៦-លោក	អ៊ុន	វិសាលភាព	អនុប្រធាននាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស
៧-លោក	ហ៊ឹម	សារុន	អនុប្រធាននាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល
៨-លោក	តោគ	សារឿន	ប្រធានការិ.នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស
៩-លោក	សំ	សាមឿន	ប្រធានការិ.នាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស
១០-លោកស្រី	សួន	ស្រី	ប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១១-លោក	គង់	វ៉ាន្នី	ប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិសៀមរាប

ខ-មេដាយប្រាក់ការងារ:

១-លោក	ឃួន	ស៊ីនាថ	អនុប្រធាននាយកដ្ឋានសេវាកម្មអាកាសចរណ៍
២-លោក	ហៀង	វណ្ណឌី	ប្រធានការិយាល័យ នាយកដ្ឋានសេវាកម្មអាកាសចរណ៍
៣-លោក	សុខ	ចាន់ធួក	ប្រធានការិយាល័យ នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន
៤-លោក	ហ៊ីង	សុធា	ប្រធានការិយាល័យ នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន
៥-លោក	ថៅ	ទ៉ាន់នី	ប្រធានការិយាល័យ នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស
៦-លោក	ខោល	សារ៉ា	ប្រធានការិយាល័យ នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស
៧-លោក	មាស	ផល្លា	ប្រធានការិយាល័យ នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស
៨-លោក	ទ៉ាន់	គី	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិ ខេត្តព្រះសីហនុ
៩-លោក	ស៊ឹម	ហេង	អនុប្រធានការិយាល័យ នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស
១០-លោក	យ៉ាន់	សុវណ្ណារ៉ា	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១១-លោក	អ៊ុំ	សួន	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១២-លោក	សេង	ណារី	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៣-លោក	ពិន្ទ	ទុត្ថា	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១៤-លោក	ឈាយ	សារូ	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១៥-លោក	កែវ	សុវណ្ណ	អនុប្រធានការិ.អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១៦-លោក	ម៉ែន	ណារង្ស	អនុប្រធានការិ.អាកាសយានដ្ឋានខេត្តស្ទឹងត្រែង
១៧-លោកស្រី	អ៊ុំ	ចន្ធី	លេខាធិការ នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ
១៨-លោក	ទី	សុវណ្ណារិទ្ធ	ភ្នាក់ងាររដ្ឋបាលអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

គ-មេដាយសំរឹទ្ធការងារ:

១-លោក	ប៉ែល	ទ៉ាន់ដេត	ប្រធានការិយាល័យ នាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
២-លោក	កង	សុធី	អនុប្រធានការិយាល័យ នាយកដ្ឋានត្រួតពិនិត្យសន្តិសុខ
៣-លោកស្រី	ស៊ីយ	សុនណារី	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
៤-លោក	ចាន់	ចំរើន	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
៥-លោក	អ៊ុង	សុគ័ត	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ
៦-លោក	ចាច់	ខេមខ្សែន	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ
៧-លោក	គិន	សារឿន	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានសេវាកម្មអាកាសចរណ៍
៨-លោក	ពិ	ម៉ារ៉ា	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស
៩-លោក	គឹម	រតនៈ	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ
១០-លោក	សារី	សំណាង	មន្ត្រីគ្រប់គ្រងរដ្ឋបាល នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ
១១-លោក	សុង	មករា	មន្ត្រីបច្ចេកទេស នាយកដ្ឋានផែនការយុទ្ធសាស្ត្រនិងគោលនយោបាយ
១២-លោក	ចាន់	សមសាត់	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៣-លោក	ចាន់	ទ៉ាន់ធឿន	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៤-លោក	ទឹម	ទួន	មន្ត្រីក្រមការ នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពហោះហើរ
១៥-លោក	នី	ទុត្ថា	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៦-លោក	ទ៉ាង	ពេជ្រ	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៧-លោក	ទេង	ធឿន	លេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

១៨-លោក	ប៊ិន	ហេង	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៩-លោក	ប៊ី	ស៊ុនហេង	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២០-លោកស្រី	កែវ	ចំនួចលំក្ខណ៍	លេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២១-លោក	សេង	ឧទ្ធី	លេខាធិការ នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពអាកាសយានដ្ឋាន
២២-លោកស្រី	ជា	សម្ផស្ស	ភ្នាក់ងាររដ្ឋបាល នាយកដ្ឋានស្តង់ដានិងសុវត្ថិភាពហោះហើរ
២៣-លោក	អ៊ុក	សុខអេង	ភ្នាក់ងាររដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ
២៤-លោក	ឃឿន	ចំរើន	ភ្នាក់ងាររដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២៥-លោក	ម៉ាន់	សុគន្ធ	ភ្នាក់ងាររដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២៦-លោក	ពុត	សុវណ្ណា	ភ្នាក់ងាររដ្ឋបាល អាកាសយានដ្ឋានខេត្តបាត់ដំបង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១០៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោក **ជ័យ តារា** មន្ត្រីសម្របសម្រួលគម្រោងអង្គការភ្លែន ប្រចាំខេត្តសៀមរាប ដែលមានស្នាដៃល្អក្នុងការស្វែងរកថវិកាសាងសង់មណ្ឌលសុខភាព និងសម្ភារៈផ្សេងៗ នៅក្នុងខេត្តសៀមរាប ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១០៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ចាំង ភាំងអ៊ាង** នាយកអង្គការបេះដូងជប៉ុន ប្រចាំនៅកម្ពុជា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារមន្ទីរពេទ្យបង្អែកពារាំង និងជួយពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible]១ ខែ វិច្ឆិកា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១១០..រសក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោកស្រី **ឈុំ បញ្ញារដ្ឋ** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ វិច្ឆិកា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការដំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
